## 1> ការអភិវឌ្ឍក្របខណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដាជាតិសមត្ថភាព និងការទទួលស្គាល់វគ្គ កម្មវិធី និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

គោលបំណងសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺរៀនចប់មានការងារធ្វើ បង្កើនប្រាក់ចំណូលធ្វើឱ្យប្រសើរឡើងនូវជីវភាព និង ជួយជម្រុញឱ្យសេដ្ឋកិច្ចជាតិមានការរីកចំរើន ។ ហេតុនេះ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទាមទារសមត្ថភាពមួយសមស្របតាមតម្រូវការទីផ្សារការងារ ដើម្បីធានាបាននូវគុណភាពបណ្តុះបណ្តាល ត្រូវមានសកម្មភាព :

- ការអភិវឌ្ឍក្របខណ្ឌគុណវុឌ្ឍិជាតិ
- ការអភិវឌ្ឍស្តង់ដាជាតិសមត្ថភាព ធ្វើតេស្ត និងទទួល ស្គាល់ សមត្ថភាព
- ការទទួលស្គាល់វគ្គកម្មវិធី និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ

### 1.1- ការអភិវឌ្ឍក្របខ័ណ្ឌគុណវុឌ្ឍិជាតិ

ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ជាមាត្រដ្ឋានមួយជាក់លាក់ របស់ជាតិ ដែលកំណត់នូវកំរិតវិញ្ញាបនបត្រ សញ្ញាបត្រ ក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ចាប់តាំងពីកំរិតទាប រហូតដល់ក្រោយឧត្តម-សិក្សា ។ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិមានសារសំខាន់សំរាប់ធ្វើសមមូល

វិញ្ញាបនបត្រ សញ្ញាបត្រ ដែលទទួលបានពីការអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ និងសញ្ញាបត្រ ខាងផ្នែកអប់រំតាមប្រព័ន្ធ Academic ។

មយ៉ាងវិញទៀត ក្របខ័ណ្ឌគុណវុឌ្ឍិជាតិក៏បានកំណត់អំពីកំរិតក្របខ័ណ្ឌក្នុងតួនាទីជាមន្ត្រីរាជការរបស់រដ្ឋ ឬ បុគ្គលិករបស់សហគ្រាសគ្រឹះស្ថាន ក្រុមហ៊ុនឯកជននានា ហើយទទួលបានកម្រៃតាមកំរិតនីមួយៗ ជាពិសេសបានផ្ដល់ឱកាសឱ្យដល់អ្នកចង់សិក្សាបន្ត មានលទ្ធភាពសិក្សារបស់ខ្លួនពីកំរិតមួយទៅកំរិតមួយទៀត ។ តាមរយៈគម្រោង"ជំនាញមូលដ្ឋាន (Basic Skills Project)" អតីតនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ បានធ្វើពង្រាងក្របខណ្ឌគុណវុឌ្ឍិជាតិមាន៧កំរិត ។ ប៉ុន្តែរហូតមកដល់ពេលនេះ ក៏ក្របខណ្ឌគុណវុឌ្ឍិជាតិមិនទាន់មានលក្ខណៈប្រើប្រាស់ជាផ្លូវការនៅឡើយ ។ ដើម្បីរៀបចំ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវក្របខណ្ឌគុណវុឌ្ឍិជាតិ ក្រសួងមានសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

- ធ្វើទំនាក់ទំនងជាមួយជំនាញការបរទេសដែលធ្វើការផ្នែក អប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីសុំបទ ពិសោធន៍ និងចំណេះដឹង
- សិក្សាស្រាវជ្រាវឯកសារបរទេសដែលពាក់ព័ន្ធការងារនេះ បន្ថែមទៀត
- បណ្ដុះបណ្ដាលសមត្ថភាពមន្ត្រីជំនាញ
- កំណត់បានក្របខណ្ឌគុណវុឌ្ឍិជាតិ

- រៀបចំប្រជុំ សិក្ខាសាលា ដើម្បីទទួលការគាំទ្រ និង ផ្សព្វផ្សាយ
- រៀបចំច្បាប់ លិខិតបទដ្ឋាននានា ដើម្បីអនុវត្ត ។

## ១១២. ការអភិវឌ្ឍស្តង់ដាជាតិសមត្ថភាព ធ្វើតេស្ត និង ទទួលស្គាល់សមត្ថភាព

ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទាមទារសមត្ថភាពមួយសមស្របតាមបទដ្ឋានបច្ចេក ទេសត្រឹមត្រូវ ។ ដូចនេះ ស្តង់ដាជាតិសមត្ថភាពត្រូវអភិវឌ្ឍជាប្រចាំតាមការរីកចំរើននៃបច្ចេក-វិទ្យា ហើយកម្មវិធីសិក្សាត្រូវផ្អែកលើស្តង់ដាជាតិសមត្ថភាពជាចាំបាច់ ។

ទន្ទឹមនឹងការអភិវឌ្ឍស្តង់ដាជាតិសមត្ថភាពក៏យើង នៅមានបញ្ហាមួយចំនួនដែលត្រូវគិត ព្រោះប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេក-ទេស និងវិជ្ជាជីវៈជាប្រព័ន្ធបណ្តុះបណ្តាលមួយអនុគ្រោះ មិនថារៀនតាមរយៈក្រុមគ្រួសារ ញាតិមិត្ត បងប្អូន ឬហ្វឹកហ្វឺន តាមការដ្ឋានការងារ ។ល។ ត្រូវទទួលស្គាល់នូវសមត្ថភាព ដែលពួកគាត់មានតាមរយៈការធ្វើតេស្តបញ្ជាក់សមត្ថភាព និងទទួលស្គាល់ដើម្បីកំណត់បាននូវលំដាប់ថ្នាក់បច្ចេកទេស/ឯកទេស តាមក៏រិតជំនាញនីមួយៗ ពិសេសការបង្ហាញពីសមត្ថភាពបច្ចេកទេសពិតប្រាកដរបស់អ្នកបច្ចេកទេស/ឯកទេសម្នាក់ៗ ។ សកម្មភាពសំខាន់ៗដែលត្រូវធ្វើឱ្យបានសម្រេចនូវគោលបំណងនេះរួមមានៈ

- បណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញ
- រៀបចំគោលនយោបាយ និងបទប្បញ្ញត្តិនានាស្តីពីស្តង់ដា

ជាតិសមត្ថភាព តេស្តបញ្ជាក់សមត្ថភាព និងការទទួលស្គាល់តាមរយៈការបង្កើតក្រុមការងារបច្ចេកទេស

- រៀបចំស្តង់ដាជាតិសមត្ថភាព ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ
- រៀបចំឱ្យមានសិក្ខាសាលា ប្រជុំ សន្និសីទ ។ល។ ដើម្បី ធ្វើការផ្សព្វផ្សាយ
- សិក្សាស្រាវជ្រាវ និងចងក្រងឯកសារស្តង់ដាសមត្ថភាព តាមជំនាញនីមួយៗ
- អភិវឌ្ឍកញ្ចប់តេស្តបញ្ជាក់សមត្ថភាព និងប្រព័ន្ធទទួល ស្គាល់សមត្ថភាព
- បង្កើត និង/ឬ ទទួលស្គាល់មជ្ឈមណ្ឌលធ្វើតេស្ត
- ធ្វើតេស្តសមត្ថភាពដើម្បីទទួលស្គាល់សមត្ថភាព និងផ្តល់ វិញ្ញាបនបត្រ/អាជ្ញាប័ណ្ណ
- ពង្រឹង និងពង្រីកភាពជាដៃគូជាមួយផ្នែកឯកជន ពិសេសខាងសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ឯកជននានា ។

### 1.3- ***ការទទួលស្គាល់វគ្គ កម្មវិធី និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ***

រៀបចំលក្ខណៈវិនិច្ឆ័យ និងក្របខណ្ឌដើម្បីធ្វើការវាយតំលៃទទួលស្គាល់គុណភាពវគ្គកម្មវិធី និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលកំពុងដំណើរការបណ្តុះបណ្តាល សំដៅធានា

គុណភាពរបស់វគ្គ កម្មវិធី និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។ សកម្មភាពដែលត្រូវអនុវត្ត ៖

- រៀបចំលក្ខណៈវិនិច្ឆ័យដើម្បីទទួលស្គាល់
- អភិវឌ្ឍគោលនយោបាយនីតិវិធីចុះបញ្ជិកា និងទទួលស្គាល់គុណភាពបណ្តុះបណ្តាល
- រៀបចំច្បាប់ លិខិតបទដ្ឋាន ដើម្បីអនុវត្ត
- ធ្វើការវាយតំលៃវគ្គ កម្មវិធី និងគ្រឹះស្ថានសិក្សាដើម្បីទទួលស្គាល់ ។